*ឈ្នះដូចគ្នា តែរាស្ត្រខ្មែរ*
*ជាអ្នកចាញ់*



# ដេកផ្សំដួល

បើស្រុកខ្មែរ ជា ប្រទេស អនុវត្តន៏ លទ្ធិប្រជាធិបេតយ្យ ពិតប្រាកដ វាគ្មានរឿងអ្វី នឹងត្រូវមាន វប្បធម៍សន្ទនា នោះឡើយ ព្រោះ ក្នុង លទ្ធិប្រជាធិបេតយ្យ ការសន្ទនា រវាងគូប្រឆាំង វាជា **តម្លៃសជ្ឈន្តិកៈ**[1] របស់ លទ្ធិប្រជាធិបេតយ្យ នេះឯង ដែលមាន ច្បាប់ជាមូលដ្ឋាន។

ដូច្នេះ ការលើកវប្បធម៍សន្ទនា មកធ្វើរបៀបដោះស្រាយបញ្ហាជាតិ គឺជាការបញ្ជាក់ឲយើញថា ស្រុកខ្មែរ មិនមែនជាប្រទេសលទ្ធិប្រជាធិបតេយ្យ នោះឡើយ។ យើងដឹងថា វប្បធម៍សន្ទនាសព្វថ្ងៃនេះ ដែលជាទំលាប់អវិជ្ជមាន មាននៅក្នុងសង្គមខ្មែរ តាំងពីបុរាណកាលមក ហើយ សម្តេច សីហនុ យកវាមកប្រើ បំពានលើកិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ១៩៩១។ វប្បធម៍ នេះ គឺជា គំនិត «**ធ្វើសិនទៅ ខុសត្រូវចាំគិត តទៅទៀត**»។ ដូចសព្វថ្ងៃ សម រង្ស៊ី អន្ទង ថា ឲរង់ចាំមើលលទ្ធផល មុននឹងរិះគន់។ យើងដឹងថា លទ្ធផល ជា ផល្លា នៃអំពើ ; បើ ជាអំពើអាក្រក់ ច្បាស់ជាមានផលអាក្រក់ ដូច្នេះការរង់ចាំវាជា ឧបករណ៏ នៃកាលៈទេសៈ[2] សំរាប់មនុស្សខូចតែប៉ុណ្ណោះ។

នៅក្នុងទស្សវត្សរ៍ ១៩៩០, សព សីហនុ ប្រឌិតថា ព្រះអង្គមាន **អសតេកិច្ឆរោគ**[3] ដើម្បី រកសេចក្តីអាសូរ ពីប្រជាពលរដ្ឋខ្មែរ ; រីឯ សម រង្ស៊ី វិញ នាបច្ចុប្បន្ននេះ គាត់ ប្រឌិត វ័យ គតិបណ្ឌិត ឬ វ័យជរា របស់គាត់ ដើម្បីរក សមានចិត្ត ពីសំណាក់ ហ៊ុន សែន សំរាប់សេចក្តីសុខផ្ទាល់របស់គាត់។ ទង្វើទាំងពីរនេះ ជា ហាសនាដកម្ម នាំឲអស់សំណើចខ្លាំង ក្លាយជា យំអណ្តឹតអណ្តន់ ទៅជា សោកនាដកម្ម ទៅវិញ។ សោកនាដកម្មនេះ គឺមាននៅក្នុង វប្បធម៍សន្ទនា រវាង សម រង្ស៊ី ជាមួយនឹង ហ៊ុន សែន ដែលមានប្រជាជនខ្មែរ ជាអ្នកទស្សនារឿងល្ខោននេះ។

---

1 តម្លៃសជ្ឈន្តិកៈ= តម្លៃមានខាងក្នុង ; Valeur intrinsèque។
2 ឧបករណ៏ នៃកាលៈទេសៈ= Instruments des circonstances។
3 អសតេកិច្ឆរោគ= Maladie incurable។

សម រង្ស៊ី បានធ្វើការបញ្ជាក់ ពីចិត្តគំនិតរបស់ខ្លួន នៅក្នុងវប្បធម៌សន្ទនា ដែលយើងទុកជាវប្បធម៌ចាញ់ៗ តាំងពីឆ្នាំ ១៩៩១ មកម្លេះ។
ចិតគំនិត សម រង្ស៊ី[4]៖

*«ជូនកាល យើងត្រូវសាលល្បងច្រើនដងណាស់ មុននឹងអាចសម្រេចបាននៅទីបញ្ចប់នូវគោលដៅរបស់យើង។ កត្តាមួយទៀត ដែលអំណោយផល គឺដោយសារតែស្ថានការណ៍នយោបាយ នៅប្រទេសកម្ពុជានៅឆ្នាំ ២០១៥នេះ ខុសប្លែកឆ្ងាយណាស់ពីឆ្នាំ ២០០៦។ ជាលើកទីមួយហើយ ពេលនេះដែលមានកម្លាំងប្រឆាំងតាមបែបប្រជាធិបតេយ្យ បានរួមគ្នាជាធ្លុងមួយ ហើយបានក្លាយទៅជាគណបក្សក្រៅរដ្ឋាភិបាលតែមួយគត់ នៅក្នុងរដ្ឋសភា។ តុល្យភាពនយោបាយថ្មីនេះ គឺការតស៊ូមតិមួយទល់នឹងមួយ បាននាំមកនូវលក្ខណៈងាយស្រួល ដើម្បីចាប់ផ្តើមការសន្ទនាមួយពិតប្រាកដ»*

**មតិ**៖ សេចក្តីព្យាយាម គឺពិតជា គុណធម៌ សំរាប់ មនុស្សលោក តែព្យាយាមធ្វើអ្វីមួយគ្មានទំនងសោះ គឺជា ការភាន់ច្រឡំ តែបើគ្មានការតម្រូវ គឺជា កំហុស ហើយបើនៅតែព្យាយាមធ្វើកំហុសនេះបន្តទៅទៀត គឺជា ទោសសីលធម៌។ ទោសនេះហើយដែល សម រង្ស៊ី កំពុងប្រព្រឹត្តក្នុងវប្បធម៌សន្ទនាដែលគាត់ខ្លួនឯងធ្លាប់យកវាមកប្រើក្នុងឆ្នាំ ២០០៦។ សម រង្ស៊ី យល់ ថា ស្ថានការណ៍ នយោបាយ នៅស្រុកខ្មែរ ក្នុងឆ្នាំ ២០០៦ និង ២០១៥ ខុសប្លែកគ្នាឆ្ងាយណាស់ តែគាត់ ជ្រើសរើស វប្បធម៌សន្ទនា ដដែល ដែលគាត់បានធ្វើនៅក្នុងឆ្នាំ ២០០៦ គឺ សន្ទនា ក្នុងឋានៈជាអ្នកចាញ់ សុំសុខ ឬ រកប្រយោជន៍ សំរាប់ខ្លួនគាត់ផ្ទាល់តែប៉ុណ្ណោះ។ ប៉ុន្តែជម្រើសនេះ គាត់សំអាង ថា នៅក្នុងឆ្នាំ២០១៥ មាន តុល្យាភាពនយោបាយថ្មី រវាង គណបក្សកាន់អំណាច នឹង គណបក្សប្រឆាំង ដែលសព្វថ្ងៃគាត់ ប្រើពាក្យថា គណបក្សនៅក្រៅរដ្ឋាភិបាល សំរាប់ផ្តើមសន្ទនាពិតប្រាកដ។

[4] ដកស្រង់ពីសម្ភាសន៍កាសែតភ្នំពេញប៉ុស្ត៍ សម រង្ស៊ី ជាភាសា អង់គ្លេស ដែលគេយកមកបកប្រែក្រៅផ្លូវការ ជាភាសាខ្មែរ។

បើរាប់ជាចំនួន ៥៥ (បក្សសង្គ្រោះជាតិ) និង ៦៨ (បក្សប្រជាជនខ្មែរ) កៅអីនៅក្នុងរដ្ឋសភា វាពិតជាមាន តុល្យភាព សំរាប់តាមពិនិត្យសកម្មភាព បក្សកាន់អំណាច ពីសំណាក់បក្សប្រឆាំង ដោយគ្មានបារម្ភពីសម្ពាធពីក្រុមអ្នកកាន់អំណាច ហើយលើកយកអ្វីដែលទុកជា អសកម្ម និង អវិជ្ជមាន របស់រដ្ឋាភិបាល ក្រុមភាគច្រើន មកបង្ហាញជូនប្រជាពលរដ្ឋ ដែលជាអធិបតីនៃប្រជាជាតិ អោយបានដឹកច្បាស់ អំពីកិច្ចការរដ្ឋ និងកិច្ចការសាធារណៈ ដែលប៉ះពាល់ដល់ប្រយោជន៏ជាតិ ឬ នាំបង្កើតវិបត្តិដល់ជាតិ។ តែតុល្យាភាព នេះ ត្រូវ បក្សសង្គ្រោះជាតិ យកមកប្រើ សំរាប់រកប្រយោជន៏បក្ស ឬ ក្រុមអ្នកដឹកនាំបក្សទៅវិញ។

តាមពិត អ្វីទៅដែលនាំចិត្ត សម រង្ស៊ី អោយជ្រើសផ្លូវចាញ់ដើរដដែល គឺ ជាមធ្យោបាយពង្រឹងអំណាចខ្លួននៅក្នុងបក្សសង្គ្រោះជាតិ ដោយប្រើអំណាច ហ៊ុន សែនជា ការគំរាមកំហែង ដល់សមាជិកណា ដែល មានគំនិតផ្ទុយពីប្រយោជន័ខ្លួន ព្រោះកិច្ចព្រមព្រៀងចូលរដ្ឋសភា នាថ្ងៃទី ២២ កក្កដា ២០១៤ រវាង ខ្លួន ជាមួយ ហ៊ុន សែន ជាកំណើត តាមដំបៀត ប្រើគៀ្បតទាញចេញទារក របស់ សម រង្ស៊ី បើនិយាយឲស្រួលស្តាប់គឺ ជាកិច្ចព្រមព្រៀងគ្មាន ឯកភាពនៅក្នុង ជួរគណបក្ស។ ត្រូវដឹងថា ជំនូនរបស់ ហ៊ុនសែន ដល់ សម រង្ស៊ី សំរាប់ កំណើត ទារក ឈ្មោះ កិច្ចព្រមព្រៀង ចូលរដ្ឋសភា វាវិសេស លើសពីការគិតចង់បាន របស់ សម រង្ស៊ី ទៅទៀត ដូចជា កៅអី តំណាងរាស្ត្រដោយមិនចាំបាច់បោះឆ្នោត, ងារដែលឲមានកិត្តិយស, **អត្ថប្រយោជន៏ជាវត្ថុប្រៀប**[5]។ល។ គួរកត់សំគាល់ថាកិច្ចព្រមព្រៀងនេះ គ្មានឯកសារ ជាផ្លូវការ សំរាប់ទុកជាសំអាង ផ្សប់ផ្សាយជាសាធារណៈជូនជាដំណឹង ដល់ប្រជាពលរដ្ឋ ដែលជាម្ចាស់អំណាចនោះឡើយ។ តែ នៅក្នុងពេលថ្មីនេះមានធ្វើសេចក្តីប្រកាសរួម នៃគោលការណ៏សីលធម៌[6]សំរាប់ដោះស្រាយ វិបត្តវិន័យបក្សនៅក្នុង គណបក្សសង្គ្រោះជាតិ តែនៅក្នុងនោះគ្មានឃើញបង្ហាញនូវអ្វី ដែលជាមូលដ្ឋាននយោបាយ សំរាប់ដោះស្រាយបញ្ហាជាតិទាល់តែសោះ។ ម្យ៉ាងមួយទៀត សេចក្តីប្រកាសនេះ ក៏ ជាចម្លើយ របស់បក្សសង្គ្រោះជាតិ សំរាប់រំងាប់កំហឹង ហ៊ុន សែន មកលើ កែម សុខា តែប៉ុណ្ណោះ។ ដូច្នេះ វប្បធម៌សន្ទនា គឺជាការដេកផ្សំដួល របស់ សម រង្ស៊ី ព្រោះទង្វើ

---

[5] អត្ថប្រយោជន៏ជាវត្ថុប្រៀប= Avantage en nature។
[6] សេចក្តីប្រកាសនៃគោលការណ៏សីលធម៌= Déclaration des principes éthiques។

នេះ វាមានប្រយោជន៏ ដល់គាត់ផ្ទាល់ ទាំងផ្ទៃក្នុង និង ផ្ទៃក្រៅ បក្ស។ តែ សម រង្ស៊ី ធ្វើមិនយល់ដឹងថា អ្វីដែលជាប្រយោជន៏គាត់ គឺជាប្រយោជន៏ ហ៊ុន សែន សំរាប់ ចិញ្ចឹមអំណាចផ្តាច់ការ។ ដូចមាននៅក្នុសំនេររបស់ទស្សនះវិទូបារាំង Jean-Jacques Rousseau ថា៖ *«អ្វីដែលខ្ញុំធ្វើការសន្ទត ជាមួយអ្នក គឺ អ្នក ជាអ្នកទទួលបន្ទុកទាំងអស់សំរាប់ប្រយោជន៏របស់ខ្ញុំ ដែលជាការពេញចិត្ត របស់ខ្ញុំ ហើយការនេះបើវា នៅមានជានិច្ចក្នុងចិត្តខ្ញុំ អ្នកក៏ត្រូវទទួលបន្ទុកនេះរហូតដែរ[7]»*។

នៅថ្ងៃទី ១៤ ឧសភា នៅសហរដ្ឋអាមេរិក ក្នុងទីក្រុង Gaithrsburg សម រង្ស៊ី លបដូរដោយប្រសប់ ពាក្យ វប្បធម៏សន្ទនា ទៅជា វប្បធម៏សន្តិភាព ព្រោះ ពាក្យសន្ទនា វាពិបាកពន្យល់ ជាង ពាក្យសន្តិភាព ហើយដើម្បី អោយសំដីគាត់វាមាន ហេតុផល ល្អទៅទៀត គាត់ បញ្ជាក់ជាសំដីខ្យល់ថា វប្បធម៏សន្តិភាព នេះ អាចការពារ បូរណភាពទឹកដីខ្មែរបាន។ ដូច្នេះខ្មែរ ត្រូវរួបរួមគ្នា អោយបានច្រើន។

យើងចង់សួរ សម រង្ស៊ីថា តើ គាត់អះអាង ដោយប្រើផែនទីស្រុកខ្មែរ នៅជំនាន់ណា ? ហើយ ការរួបរួមនោះទៀត នៅជុំវិញនរណា ?៖ គូ ហ៊ុនសែន/សមរង្ស៊ី ?
តែអ្វីដែល សម រង្ស៊ី ភូតកុហក ក៏នៅតែខ្មែរ មួយជំនួន នាំគ្នាចាំមើលសិន ព្រោះ «ធ្វើសិន» ឬ «ចាំមើលសិន» នេះ ជាវប្បធម៏ហែអើ របស់ខ្មែរយើង ឬ វប្បធម៏ ដេកផ្សំដួល ព្រោះវា ជាវប្បធម៏ ងាយស្រួលបំផុត សំរាប់យកមកអនុវត្តន៏។៚

---

[7] Je fais avec toi une convention toute à ta charge et toute à mon profit, que j’observe tant qu’il me plaira et que tu observeras tant qu’il me plaira។

និពន្ធដោយ ឧប សៅ សង្ហា
ថ្ងៃទី ១៦ មិថុនា ២០១៥